# អ្នកដែលត្រូវចោទប្រកាន់ក្នុងករណី០០៤ ត្រូវបានលើកមកនិយាយ : សក្ខីកម្មរបស់ជនជាប់ចោទ នួន ជា និង សាក្សី ប្រាក់ យុត

*វ៉េនឌុល ឌីហ្សាល់កូ*

*ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២*

*ប្រែសម្រួលដោយ ផា ផល្លា*

*"ខ្ញុំមកតុលាការនេះ ដោយគ្មាននរណាគម្រាមកំហែងខ្ញុំទេ... គ្មាននរណាបង្ខាត់ខ្ញុំឲ្យនិយាយទេ"*
*-ប្រាក់ យុត*

នៅថ្ងៃចន្ទ ទី៣០ ខែមករា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមការសួរសំណួរទៅកាន់ នួន ជា ។ ចំណែកសាក្សី ប្រាក់ យុត បានបញ្ចប់សក្ខីកម្មរបស់គាត់នៅពេលរសៀល ។

## ព្រះរាជអាជ្ញាសួរទៅកាន់ នួន ជា

ចៅក្រម និល ណុន ចាប់ផ្តើមដំណើរការនៅថ្ងៃនេះដោយរំឭកទៅព្រះរាជអាជ្ញាថា សំណួរដែលសួរត្រូវតែមានដែនកំណត់ពេលព្រឹកបានហើយ ។ ក្រោយពីនិយាយចប់ លោកប្រធានចៅក្រមបានប្រគល់តួនាទីនេះ ទៅ ដា លីសាក់ ដើម្បីសួរសំណួរទៅកាន់ នួន ជា ។ ដំបូង ដា លីសាក់ បានសួរទៅ នួន ជា អំពីសេចក្តីសម្រេចរបស់ខ្មែរក្រហមក្នុងការលុបបំបាត់ចោលទ្រព្យសម្បត្តិឯកជននាដើមទសវត្សរ៍៧០ ។ នួន ជា បានឆ្លើយថា "មិនមានការលុបបំបាត់ចោលទ្រព្យសម្បត្តិឯកជនទេ" នៅពេលនោះ តែខ្មែរក្រហមមានគោលនយោបាយមួយ គឺ"ការបែងចែកដីធ្លី" ។ ដា លីសាក់ បានអានអត្ថបទមួយដែលចម្លងចេញពីទស្សនាវដ្តីទង់បដិវត្តន៍របស់ខ្មែរក្រហមដែលបានបញ្ជាក់ថា មេដឹកនាំខ្មែរក្រហមបានរៀបចំកិច្ចប្រជុំជាបន្ទាន់មួយក្នុងឆ្នាំ១៩៧២ ព្រោះសមាជិកខ្លះនៅក្នុងចលនារបស់ខ្លួននៅវក្សាជំហរ"សក្តិភូមិ" និង"វណ្ណៈគហបតី" ។ នួន ជា បានឆ្លើយថា គាត់មិនមែនមានតំណែងនៅក្នុងរដ្ឋបាលទេ ហើយគាត់ចូលរួមពាក់ព័ន្ធតែជាមួយ"កិច្ចការអប់រំ"ប៉ុណ្ណោះ ។ នួន ជា បានថ្លែងដូចទៅនឹងអ្វីដែលគាត់ធ្លាប់បានអះអាងពីមុនហើយ ហើយក្រោយមកគាត់បានបកស្រាយថា តួនាទីរបស់គាត់ក្នុងរបបខ្មែរក្រហម គឺទទួលមុខងារខាងការអប់រំ និងឃោសនាប៉ុណ្ណោះ ហើយថា ចលនាខ្មែរក្រហមបានបែងចែករចនាសម្ព័ន្ធបញ្ជាដាច់ដោយឡែកពីគ្នា ។

ក្រោយពីសួរសំណួរបន្ថែមទៀត នួន ជា បានផ្តល់សក្ខីកម្មថា សហករណ៍មិនត្រូវបានបង្កើត "ជាប្រព័ន្ធ" ដោយចលនាខ្មែរក្រហមទេ តែសហករណ៍ត្រូវបានបង្កើតឡើង "ចេញពីជនបទ"ម្តងមួយៗ ដូច្នេះខ្មែរក្រហមមិនមានកាលបរិច្ឆេទថ្ងៃ ខែ ឆ្នាំ ដែលសហករណ៍បានបង្កើតទេ។ នួន ជា បានពន្យល់ថា ដំបូងខ្មែរក្រហមបង្កើតសហករណ៍កម្រិតទាប និងក្រោយមកបង្កើតសហករណ៍កម្រិតខ្ពស់ ហើយថា មេដឹកនាំខ្មែរក្រហមបានអះអាងថា ការបង្កើតសហករណ៍អាចជៀសផុតពីការចំណាយពលកម្ម និងម្ហូបអាហារច្រើនក្នុងបណ្តាកសិករ។

ជា លីសាក់ បានសួរអំពីអ្វីដែលខ្មែរក្រហមបានសរសេរដែលបញ្ជាក់ថា ការបង្កើតសហករណ៍អាច "ផ្តួលរំលំអំណាចសក្តិភូមិ ម្ចាស់ដី និងមូលធននិយម"។ នួន ជា បានឆ្លើយដោយបដិសេធម្តងទៀតថា គាត់មិនបានចូលរួមទាក់ទងក្នុងការបង្កើតគោលនយោបាយរបស់ខ្មែរក្រហមទេ។ តួនាទីរបស់គាត់គឺត្រឹមតែអប់រំមួយមុខគត់ តែគាត់បាននិយាយថា សហករណ៍ត្រូវបានបង្កើតដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ នៅពេលសួរអំពីដំណាក់កាលដើមទសវត្សរ៍៧០ នួន ជា បានបញ្ជាក់ថា សហករណ៍មិនត្រូវបានដំណើរការភ្លាមៗទេ ហើយថា កិច្ចការសំខាន់គឺទាក់ទងទៅនឹងកិច្ចការអប់រំនយោបាយ ពីព្រោះប្រជាជនដែលរស់នៅក្នុងរបបដែលគ្រប់គ្រងដោយខ្មែរក្រហម មិនសូវមានចំណេះដឹងច្រើនអំពីមនោគមន៍វិជ្ជាបក្សដើម្បីអនុវត្តផែនការសហករណ៍នៅគ្រប់តំបន់ទេ។

ក្រោយមក ព្រះរាជអាជ្ញាបានប្តូរប្រធានបទសួរទៅកាន់ នួន ជា អំពីទីតាំងដែលគាត់នៅតាំងពីមុនរបបខ្មែរក្រហមរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នួន ជា ហាក់បីដូចជាមានការភាន់ច្រឡំទៅនឹងសំណួរនោះ តែបែរជាឆ្លើយអំពីពេលដែលគាត់តាំងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ទៅវិញ។ ដោយសារមានការបញ្ជាក់ពី ជា លីសាក់ រួចមក នួន ជា បានសួរព័ត៌មានបន្ថែមទៀតទាក់ទងទៅនឹងផលពិបាកក្នុងការបកប្រែ។ ក្រោយពីពិភាក្សារួចអំពីការបកប្រែសំណួរ ដែលសួរដោយព្រះរាជអាជ្ញា នួន ជា បានបញ្ជាក់ប្រាប់ថា គាត់បានទៅភ្នំពេញកាលពីដើមឆ្នាំ១៩៧៥។ ក្រោយមកព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថា តើក្នុងចន្លោះពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៥តើ អៀង សារី បានត្រលប់មកប្រទេសកម្ពុជាប៉ុន្មានដងពីទីក្រុងប៉េកាំង។ នួន ជា បានឆ្លើយថា អៀង សារី ត្រលប់មកប្រទេសកម្ពុជាចំនួនពីរដងក្នុងអំឡុងពេលនោះ ហើយបញ្ជាក់ទៀតថា ក្នុងនោះគាត់បានអម "សម្តេចសីហនុ" ពេលព្រះអង្គមកខេត្តសៀមរាប តែគាត់មិនចាំពេលណាទៀតទេ។ នៅពេលសួរអំពីព័ត៌មានផ្សេងទៀត នួន ជា បានឆ្លើយថា ប៉ុល ពត បានណែនាំគាត់ថាមិនត្រូវខ្វល់ខ្វាយទៅនឹងកិច្ចការរបស់ "បញ្ញាវន្ត" ទេ ហើយត្រូវតែផ្តោតទៅលើកិច្ចការអប់រំមួយបានហើយ ដូច្នេះគាត់មិនខ្វល់ខ្វាយពីដំណើរទស្សនកិច្ចរបស់ អៀង សារី ទេ។

លីសាក់ បានត្រលប់ទៅរកអត្ថបទមួយដែលចុះផ្សាយក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ដែល នួន ជា បានរៀបរាប់អំពីវិធីក្នុងការ«រំដោះ»តំបន់រំដោះ ដូចជាតំបន់ខុដ្ដក្ក ។ នួន ជា បានឆ្លើយថា មិនមាននរណាជូនដំណឹងមកគាត់អំពីសកម្មភាពយោធាទេ ព្រោះកិច្ចការយោធាគឺជាភារកិច្ចរបស់ សុន សេន និង ប៉ុល ពត ប៉ុណ្ណោះ ។ នួន ជា បានឆ្លើយថា ខ្មែរក្រហម«ជម្លៀសប្រជាជន ដូច្នេះប្រជាជនទាំងនោះអាចធ្វើស្រែនិងចិញ្ចឹមខ្លួនឯងបាន» នៅក្នុងសហករណ៍ ព្រោះនៅទីក្រុងភ្នំពេញមិនមានអាហារគ្រប់គ្រាន់ទេ ។ លីសាក់ បានអានសន្ទរកថា ដកស្រង់មួយរបស់ ខៀវ សំផន ដែលនិយាយថា ទាហានខ្មែរក្រហមបានសម្លាប់សត្រូវចំនួន៥០០០នាក់ក្នុងស្រុកខុដ្ដក្ក និងចាប់បានទាហាន លន់ នល់ ចំនួន ១៥០០នាក់ថែមទៀត ។ គាត់បានសួរទៅ នួន ជា ថាតើក្រោយពីចាប់បានទាហានទាំងនោះហើយយកឈ្លើយសឹកនោះទៅណា? នួន ជា បានបដិសេធថា គាត់មិនដឹងរឿងនេះទេ ហើយបានស្នើទៅព្រះរាជអាជ្ញាឲ្យសួរទៅ ខៀវ សំផន ផ្ទាល់ ។

ក្រោយមក លីសាក់ បានសួរអំពីពាក្យ «ការតស៊ូវណ្ណៈ»ដែលប្រើដោយខ្មែរក្រហម ។ នួន ជា បានបដិសេធថា បក្សមិនបានធ្វើការ«តស៊ូវណ្ណៈ»ទេ តែបក្សលើកទឹកចិត្តប្រជាជនឲ្យធ្វើការជាមួយគ្នានៅក្នុងសហករណ៍ដើម្បីជួយចិញ្ចឹមគ្នាទៅវិញទៅមក ។ គាត់បានបន្ថែមទៀតថា ថ្នាក់ដឹកនាំគ្រាន់តែជួយណែនាំឲ្យសមាជិកបក្សថាមិនត្រូវលេងល្បែង ញ៉ែស្រី និងធ្វើអំពើមិនគប្បី និង«មិនត្រូវប្រើអំណាចដែលខ្លួនមានទៅជិះជាន់ប្រជាជន» ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរអំពីប្រធានបទអំពីសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ នួន ជា បានឆ្លើយថា ក្នុងពេលប្រជុំមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពិភាក្សាអំពីសេចក្ដីសម្រេចដោយសហរដ្ឋអាមេរិក ដែលបានបញ្ឈប់ការទម្លាក់គ្រាប់បែកក្នុងប្រទេសកម្ពុជា ។ បក្សកុម្មុយនីស្តកម្ពុជាបានសង្កេតឃើញថា ជំនួយរបស់អាមេរិកដែលផ្ដល់ជូន លន់ នល់ រួមមាន ម្ហូបអាហារផង ដូច្នេះគណៈមជ្ឈិមក៏សម្រេចជម្លៀសប្រជាជនចេញពីទីក្រុង«បណ្ដោះអាសន្ន» ដើម្បីដោះស្រាយបញ្ហាខ្វះខាតម្ហូបអាហារនេះ ។ កាលនោះ កិច្ចប្រជុំត្រូវបានធ្វើឡើងនៅជិតស្ទឹងជីនិត អស់រយៈពេលបីថ្ងៃ ហើយអ្នកតំណាងមកពីគ្រប់ភូមិភាគទាំងអស់បានចូលរួមក្នុងនោះរួមមាន ប៉ុល ពត, រូបគាត់ផ្ទាល់, តាម៉ុក, សោ ភឹម, កុយ ធួន និង សុន សេន និងមានអ្នកផ្សេងទៀតដែលគាត់មិនចាំឈ្មោះ ។

លីសាក់ បានត្រលប់ទៅសួរអំពីគោលនយោបាយទាក់ទងទៅនឹងការជម្លៀសទីក្រុងភ្នំពេញ ។ ដំបូង លីសាក់ បានសួរថាតើហេតុអ្វីអ្នកខ្លះមានអាហារហូបគ្រប់គ្រាន់ហើយអ្នកដែលចង់នៅផ្ទះបែជាជម្លៀសទៅវិញ ។ នួន ជា បានឆ្លើយថា អាហារមានការខ្វះខាតជាខ្លាំង មានតែ«ក្រុមពាល និង

កម្មាភិបាលខ្មែរក្រហមមួយចំនួនប៉ុណ្ណោះ» ដែលបានប្រមែប្រមូលអាហារគ្រប់គ្រាន់ ដើម្បីហូបនៅក្នុងទីក្រុង ។ គណៈកម្មការពិសេសមួយដែលដឹកនាំដោយ សុន សេន មានទួនាទីអនុវត្តផែនការជម្លៀសប្រជាជនចេញពីទីក្រុងតែគណៈមជ្ឈិមជាអ្នកសម្រេចទីក្រុងទាំងមូលក្នុងឆ្នាំ១៩៧៤ នៅក្នុងកិច្ចប្រជុំពេញអង្គ ។ នួន ជា បាននិយាយថា ការជម្លៀសនេះគឺគ្រោងនឹងធ្វើ«បណ្តោះអាសន្ន»ប៉ុណ្ណោះ ដោយផ្អែកលើ«ស្ថានភាពសំខាន់ៗ»ចំនួនពីរ ។ ទីមួយ គឺ«សង្រ្គាមដែលអាចនឹងកើតមានជាមួយវៀតណាម» និងទីពីរ គឺការខ្វះខាតម្ហូបអាហារក្នុងទីក្រុងទាំងមូលទូទាំងប្រទេស ។ ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ហេតុផលថា វាមានសុវត្ថិភាពជាងបើសិនជាប្រជាជនត្រូវបានបញ្ជូនចេញពីទីក្រុងទៅកាន់ទីជនបទ ព្រោះតែមានសម្ពាធពីវៀតកុង និងសហរដ្ឋអាមេរិក ដែលក្រុមទាំងពីរនេះបក្សខ្លាចនឹងមានការវាយប្រហារ ។

ការជម្លៀសនោះមិនត្រូវបានធ្វើឡើងសម្រាប់ទាំងអស់គ្នាទូទាំងទីក្រុងនោះទេ តែអ្នកជម្លៀសទាំងអស់បានជួយគ្នាទៅវិញទៅមកដោយជួយដឹកឥវ៉ាន់ និងធនធានផ្សេងទៀត ដូចជា រទេះ និងយានយន្តជាដើម ។ បក្សកុម្មុយនីស្តកម្ពុជាមានក្តីបារម្ភថា សហរដ្ឋអាមេរិកអាចនឹងវាយប្រហារក្រោយពេលដែលខ្មែរក្រហមដណ្តើមអំណាចបានហើយ ហើយថា បក្សខ្លាចវៀតកុងមិនចូលមកជួយពេលដែលអាមេរិកចូលមកវាយ តែវៀតកុងអាចនឹងប្រើរថក្រោះដើម្បីបានឱកាសវាយប្រទេសកម្ពុជាដោយខ្លួនឯង ។ នួន ជា បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាជឿថា វៀតកុងមានការប្រណែនទៅនិងជ័យជម្នះរបស់ខ្មែរក្រហមដែលបានរំដោះទីក្រុងភ្នំពេញមុនពេលវៀតកុងរំដោះបានវៀតណាមខាងត្បូង ។

ក្រោយមក លីសាក់ បានសួរថាតើបក្សកុម្មុយនីស្តកម្ពុជាមានបានសម្រេចថាមិនបញ្ចូលបក្សថ្មីទៀតទេ ។ បើសិនជាមានការសម្រេចដូច្នេះមែន តើហេតុអ្វី? នួន ជា បានឆ្លើយដោយនិយាយពីការគម្រាមកំហែងមួយទៀតក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរក្រហម ។ ក្រុម«សមាសភាព»មិនល្អមួយចំនួនបានបង្កើតចលនាផ្សេងៗនៅពេលនោះក្រោម«លេសដើម្បីបដិវត្តន៍» ហើយក្រុមនោះបានឆក់ប្លន់ និងទ្រព្យសម្បត្តិប្រជាជនអំឡុងពេលនៃការជម្លៀស ។ នួន ជា បានរៀបរាប់ឈ្មោះក្រុមក្បត់មួយចំនួន ហើយក្រុមមួយនោះចងសម្ព័ន្ធមិត្តជាមួយវៀតណាមខាងត្បូង ។ ទីបំផុត «ទ្វារមិនត្រូវបានបិទទេ» ក្នុងឆ្នាំ១៩៧៤ សម្រាប់អ្នកដែលចង់ចូលបក្សកុម្មុយនីស្តកម្ពុជា ហើយសមាជិកត្រូវបានជ្រើសរើសដោយប្រយ័ត្នប្រយែងដោយមិនចេះតែឲ្យចូលតាមចិត្តនោះទេ ។ ក្រោយមក នួន ជា បានមករៀបរាប់ថាអំឡុងពេលដែលសង្រ្គាមជាមួយ លន់ នល់ បានបញ្ចប់ ពេលនោះស្ថានភាពមានការ«ច្របូកច្របល់»ជាខ្លាំង ពេលដែលអាមេរិកបានទម្លាក់គ្រាប់បែក«អស់រយៈពេល២០០ថ្ងៃ ២០០យប់»ដែលសម្លាប់មនុស្សជាច្រើន ហើយពេលនោះ មានក្រុមមួយចំនួនមានបំណងចង់ផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា ។

ព្រះរាជអាជអាជ្ញាបានសួរបន្តទៀតអំពីសត្រូវផ្ទៃក្នុង និងអំពីបន្សុទ្ធកម្មរបស់កម្មាភិបាលបក្សក្នុងខេត្តកោះកុង ។ នួន ជា បានឆ្លើយថា កោះកុងមិនមានបញ្ហាអ្វីទេនៅពេលនោះ តែកន្លែងដែលមានបញ្ហាគឺភូមិភាគបូព៌ានៅជិតព្រំដែនវៀតណាម ។ កាលនោះប្រជាជនវៀតណាមរាប់ម៉ឺននាក់រស់នៅក្នុងភូមិភាគបូព៌ាដែលទីនោះមិនសូវមានអាហារគ្រប់គ្រាន់ទេ ។ ខ្មែរក្រហម គឺជាអ្នកជួយទាហានវៀតកុងទាំងនោះដោយសារតែវៀតកុងមកតាំងទីលំនៅក្នុងប្រទេសកម្ពុជា ហើយរីករាយនឹងការជួយឧបត្ថម្ភទាំងអស់នោះពីបក្សកុម្មុយនីស្តកម្ពុជាអំឡុងពេលសង្គ្រាមវៀតណាម ។ នួន ជា បានរក្សាជំហរថា «អ្នកដែលមិនស្គាល់សភាពការច្បាស់បានបញ្ជាក់ថា វៀតណាមបានជួយកម្ពុជាច្រើនណាស់» តែតាមពិត វៀតណាមមិនបានជួយទេ ។

ទោះបីជា នួន ជា ឆ្លើយសំណួរទាក់ទងទៅនឹងភូមិភាគបូព៌ាក៏ដោយ លីសាក់ បានបន្តសួរទៀតអំពីកម្មាភិបាលបក្សនៅខេត្តកោះកុងម្នាក់ឈ្មោះ ឆុង ។ នួន ជា បានបញ្ជាក់ថា ឆុង ត្រូវបានកោះហៅឲ្យមកជួប តាម៉ុក តែគាត់ត្រូវបានវាយឆ្មក់និងសម្លាប់ដោយចោរព្រៃតាមផ្លូវពេលមកជួបជាមួយ តាម៉ុក ហើយគាត់ដឹងតែប៉ុណ្ណោះ ។ សំណួរចុងក្រោយដែលសួរដោយព្រះរាជអជ្ញាគឺ ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែលនិយាយអំពី«កំពូលជនក្បត់របស់ លន់ នល់ ទាំងប្រាំពីរនាក់» ដែលនឹងត្រូវយកសម្លាប់ចោល ។ លីសាក់ បានសួរថាតើ នួន ជា មានយល់ព្រមជាមួយនឹងសេចក្តីសម្រេចនេះដើម្បីសម្លាប់បុគ្គលទាំងនេះទេ ។ នួន ជា បានឆ្លើយថា គាត់មិនដឹងពីសេចក្តីសម្រេចនេះទេ តែគាត់បានឮការប្រកាសពីសេចក្តីសម្រេចនេះតាមវិទ្យុនៅពេលនោះ ។ ព្រះរាជអាជ្ញាបានស្នើទៅ នួន ជា ឲ្យផ្តល់យោបល់ទាក់ទៅនឹងសេចក្តីសម្រេចនេះ តែត្រូវមេធាវីរបស់ នួន ជា ជំទាស់ ។ នួន ជា បានឆ្លើយថា ដោយសារតែកិច្ចការរបស់គាត់ទាក់ទងទៅនឹងការអប់រំ ដូច្នេះ គាត់មិនពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចក្នុងការសម្លាប់នេះទេ ហើយសេចក្តីសម្រេចនេះ គឺការយោធាជាអ្នកចាត់ការ ។ ព្រះរាជអាជ្ញាបានសួរថា តើគណៈកម្មាធិការមជ្ឈិម និងគណៈអចិន្ត្រៃយ៍មានបានសម្រេចសម្លាប់មនុស្ស«ទាំងប្រាំពីររូប»ដែរឬទេ? នួន ជា បានឆ្លើយថា គាត់មិនដឹងទេ ។

## អៀង សារី សុំទោសម្រាកដូចសព្វដង

មេធាវីការពារក្តីរបស់ អៀង សារី បានជូនដំណឹងថា អៀង សារី សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការ និងចង់ទៅស្តាប់នៅបន្ទប់រង់ចាំជំនួសវិញ ។ សំណើនេះត្រូវបានយល់ស្របដូចសព្វដងដែរ តែអង្គជំនុំជម្រះទាមទារឲ្យប្រគល់លិខិតជាលាយលក្ខណ៍អក្សរ ។

## *ព្រះរាជអាជ្ញាបន្តការសាកសួរទៅ នួន ជា*

*ក្រោយពីសម្រាករួច ព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃៀង បានបន្តសួរទៅ នួន ជា ។ ប្រធានបទដែលត្រូវសួរនេះ គឺទាក់ទងទៅនឹងចំណារសរសេរដៃដែល នួន ជា បានសរសេរពេលដែលគាត់ផ្តល់សក្ខីកម្មកាលពីលើមុន ដែលចំណារនោះបានផ្តល់ជូនគ្រប់ភាគីទាំងអស់ ។ សេង ប៊ុនឃៀង បានសួរទៅ នួន ជា ឲ្យបញ្ជាក់ឲ្យច្បាស់នូវចំណុចមួយចំនួននៃចំណារនោះថា ពិបាកអានណាស់ ។ នួន ជា បានបញ្ជាក់នូវចំណុចដែលមានភាពមិនច្បាស់លាស់មួយចំនួននៅក្នុងឯកសារដែលគាត់បានសរសេរនោះ ទាក់ទងទៅនឹងចលនាប្រដាប់អាវុធខ្មែរក្រហមនាដំណាក់កាលដំបូង រដ្ឋប្រហារ លន់ នល់ និងការចោទប្រកាន់ផ្សេងទៀតថា វៀតណាមមានបំណងលេបទឹកដី ។*

*ទាក់ទងទៅនឹងសៀវភៅទង់បដិវត្តន៍ នួន ជា បានផ្តល់សក្ខីកម្មថា សៀវភៅនោះត្រូវបានចាត់ទុកថា "ការសម្ងាត់" មុនថ្ងៃជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ សៀវភៅនោះផ្តល់ជូនតែកម្មាភិបាលមួយចំនួនប៉ុណ្ណោះ ។ កាលនោះ សៀវភៅនោះ ត្រូវបានបោះពុម្ពដោយដៃ និងចែកចាយដោយសម្ងាត់ ព្រោះរដ្ឋាភិបាល លន់ នល់ អាចចាប់អ្នកដែលរៀបរាប់នៅក្នុងសៀវភៅនោះទាំងអស់ ។*

*ព្រះរាជអាជ្ញាបានសួរ នួន ជា អំពីការអប់រំនៅប្រទេសថៃ និងដំណាក់កាលដំបូងនៃការចូលក្នុងចលនាកុម្មុយនីស្តក្នុងប្រទេសកម្ពុជា ។ នួន ជា បានបញ្ជាក់ថា គាត់បានប្រើឈ្មោះថៃមួយកាលពីគាត់នៅរៀន គាត់បានចូលរួមជាមួយចលនាសិស្ស"ចម្រើន" នៅពេលនោះ ។ ជនកុម្មុយនីស្តកម្ពុជាបានដឹងពីសកម្មភាពរបស់ នួន ជា នៅប្រទេសថៃ ហើយបានអញ្ជើញគាត់ឲ្យចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ នៅពេលដែលគាត់ត្រលប់មកកម្ពុជាវិញ គាត់ត្រូវបានអញ្ជើញឲ្យចូលក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនដែរ ។*

*ជាទូទៅ ជនកុម្មុយនីស្តកម្ពុជាមាន"បែបបទ"ក្នុងការជ្រើសរើសបេក្ខជន ។ បេក្ខជននីមួយៗត្រូវតែជ្រើសតាំងដោយសមាជិកបក្សបីរូប ហើយត្រូវតែស្បថចំពោះគោលនយោបាយបក្ស និងលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនសម្រាប់"ផលប្រយោជន៍រួម" ។ បេក្ខជនត្រូវបានសាកល្បងការងារ និងវាយតម្លៃពីការងារជាមុនសិនមុននឹងក្លាយជាសមាជិពេញសិទ្ធិ ។*

*ទាក់ទងទៅនឹងការក្លាយជាថ្នាក់ដឹកនាំជាន់ខ្ពស់ នួន ជា បាននិយាយថា ដំបូងសមាជិកបក្សត្រូវតែធ្វើជាអ្នកដឹកនាំតាមមូលដ្ឋានជាមុនសិន ហើយត្រូវឡើងតាមឋានៈតាមខ្សែរបណ្តោយម្តងបន្តិចៗ ។ ដើម្បីធ្វើជាកម្មាភិបាលជាន់ខ្ពស់បាន សមាជិកបក្សត្រូវតែតាំងចិត្តឲ្យបានមាំមួនចំពោះចលានានឹងត្រូវខិតខំធ្វើការ ។ "បញ្ហាសំខាន់គឺថា សមាជិកបក្សត្រូវតែមានប្រវត្តិរូបល្អ" ដែលមានន័យថា កើតចេញ*

ពីត្រកូលកសិករ ។ អ្នកផ្សេងទៀតក៏អាចចូលជាសមាជិកបក្សដោយមិនគិតពីប្រវត្តិរូបដែរ តែត្រូវឆ្លងកាត់ដំណាក់សាកល្បងចំនួនពីរឆ្នាំសិន ។

សេង ប៊ុនឃៀង បានសួរទៅ នួន ជា ថាពេលណាទើបគាត់ជួប ខៀវ សំផន លើកដំបូង ។ នួន ជា បានឆ្លើយថា គាត់ជួប ខៀវ សំផន «នៅក្នុងព្រៃ» តែគាត់មិនចាំថ្ងៃខែទេ ។

ក្រោយមក ប៊ុនឃៀង បានសួរអំពីបទសម្ភាសដែលអ្នកសារព័ត៌មានមួយរូបបានសួរទៅ នួន ជា ដើម្បីចុះផ្សាយក្នុងសារព័ត៌មានបាងកកប៉ុស្តិ៍ ។ ដំបូង នួន ជា បានឆ្លើយថា គាត់មិនចាំអំពីការសម្ភាសនោះទេ ។ ក្រោយមក អត្ថបទនោះត្រូវបានបញ្ចាំងនៅលើផ្ទាំងអេក្រង់កុំព្យូទ័រ ។ នួន ជា បានបញ្ជាក់ថា គាត់នឹកមិនឃើញទេ ។ ព្រះរាជអាជ្ញាបានសួរសំណួរផ្សេងទៀតទាក់ទងទៅនឹង នួន ជា ដែលនិយាយថា គាត់ត្រូវបានចាត់ចូលជាសមាជិកគណៈមជ្ឈិមក្នុងឆ្នាំ១៩៥១ ។ នួន ជា បានឆ្លើយតបថា គាត់មិនដឹងអំពីសៀវភៅនេះទេ ហើយថា ក្នុងឆ្នាំ១៩៥១ គាត់គ្រាន់តែជាសមាជិកបក្សប៉ុណ្ណោះដែលទទួលបន្ទុកកិច្ចការឃោសនានិងអប់រំ ។ គាត់ត្រួតពិនិត្យសារព័ត៌មាននិងធ្វើការទាក់ទងជាមួយនឹងការចែកចាយឃោសនានៅតាមមូលដ្ឋាន ។

សេង ប៊ុនឃៀង បានសួរអំពីថាតើនរណាជាអ្នកគាក់តែងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងទសវត្សរ៍៥០និង៦០ ។ នួន ជា បានឆ្លើយថា «កាលពីដំបូង» ទូ សាមុត, ប៉ុល ពត និងរូបគាត់ផ្ទាល់ជាអ្នកគាក់តែងគោលនយោបាយនេះ ។

## នួន ជា បញ្ចប់ការធ្វើសក្ខីកម្ម និងស្នើសុំតាមដានដំណើរការសវនាការពីបន្ទប់រង់ចាំ

មុននឹងអង្គជំនុំជម្រះប្រកាសសម្រាកពេលរសៀល មេធាវីការពារក្តីរបស់ នួន ជា បានជូនដំណឹងទៅអង្គជំនុំជម្រះថា នួន ជា លះបង់សិទ្ធិមិនទៅក្នុងបន្ទប់សវនាការ ។ អង្គជំនុំជម្រះយល់ព្រមនឹងណែនាំមេធាវីឲ្យប្រគល់លិខិតដែលចុះហត្ថលេខាដោយ នួន ជា ។ ក្រោយមក អង្គជំនុំជម្រះបានជម្រាបថា ការសួរសំណួរទៅកាន់ ប្រាក់ យុត នឹងបន្តធ្វើនៅពេលរសៀលនេះ រួចចៅក្រមប្រកាសសម្រាកអាហារថ្ងៃត្រង់ ។

## សក្ខីកម្មរបស់ ប្រាក់ យុត បន្តជាមួយនឹងការសួរសំណួរដោយមេធាវីរដ្ឋប្បវេណី

ក្រោយពីសម្រាក ដើម្បីបណ្តឹងរដ្ឋប្បវេណីទទួលបានរយៈពេល១៥នាទីបន្ថែមទៀត ដើម្បីដាក់ជាសំណួរទៅកាន់ ប្រាក់ យុត ដោយសារតែអស់ពេលវេលាពេលដែលភាគីនេះបានសួរកាលពីលើកមុន ។ អង្គជំនុំជម្រះបានរំឭកទៅគ្រប់ភាគីទាំងអស់ថា មិនត្រូវប្រើសក្ខីកម្មរបស់សាក្សីផ្សេងទៀតទេពេលដែលកំពុងសួរសំណួរទៅកាន់សាក្សីណាមួយ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីលីពីន ស៊ុតហ្ស៍ បានរំពុកទៅ ប្រាក់ យុត អំពីតួនាទីរបស់គាត់ក្នុងនាមជាសាក្សី ដោយមិនមែនជាជនជាប់ចោទទេ ។ ក្រោយមក ហ៊ីលីពីន ស៊ុតហ្ស៍ បានសួរទៅ ប្រាក់ យុត ថាតើគាត់មិនដឹងពុំពីមន្ទីរសន្តិសុខដែរឬទេក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ? ប្រាក់ យុត បានឆ្លើយថា គាត់ "ទទួលបន្ទុកខាងកិច្ចការសន្តិសុខ" នៅជុំវិញតំបន់ភ្នំប្រុស និងផ្តល់"ការអប់រំ" ដល់អ្នកដែលប្រព្រឹត្តិខុសនឹងត្រូវបញ្ជូនទៅការិយាល័យស្រុកដើម្បីទទួល"ការអប់រំ" ។ ក្រោយមក ហ៊ីលីពីន ស៊ុតហ្ស៍ បានសុំការអនុញ្ញាតទៅអង្គជំនុំជម្រះដើម្បី "និយាយសំដៅ" ទៅលើកក្រដាស់ព័ត៌មាន ខ្លះរបស់ជនរងគ្រោះ ដែល ហ៊ីលីពីន ស៊ុតហ្ស៍ បានសំអាងទៅលើមន្ទីរសន្តិសុខភ្នំប្រុស ហើយមានអានឈ្មោះក្នុងនោះ គាត់ចង់អានឈ្មោះនោះម្តងមួយៗដើម្បីឲ្យសាក្សីស្តាប់ ។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានប្រើប្រាស់ពេលរបស់ខ្លួនអស់ហើយដែលមានរយៈពេល១៥នាទី ក្រោយមក ចៅក្រមទាំងអស់បានពិភាក្សាគ្នាអស់រយៈពេលជាច្រើននាទីមុននឹងធ្វើការសម្រេចចិត្ត ។ ចៅក្រម ស៊ីលវៀ ខាត់វ៉ាយត៍ បានសួរដើម្បីឲ្យបញ្ជាក់ឲ្យច្បាស់អំពីក្រដាសព័ត៌មានរបស់ជនរងគ្រោះ ហើយបានជូនដំណឹងទៅភាគីដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះនឹងធ្វើការសម្រេចទាក់ទងទៅនឹងបញ្ហានេះពេលក្រោយ ។

ដោយសារមានបញ្ហាក្នុងការបកប្រែ មេធាវី ម៉ៃឃើល ខារណាវ៉ាស របស់ អៀង សារី បានជំទាស់ទៅនឹងការសួរសំណួររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវី ខារណាវ៉ាស់ បានអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីបានសួរដោយដាក់បន្ទុកលើខ្លួនឯងរបស់សាក្សី ហើយមេធាវីបានស្នើឲ្យអង្គជំនុំជម្រះណែនាំទៅសាក្សី ប្រាក់ យុត ថាមិនត្រូវឆ្លើយតបពេលដែលសួរអំពីសំណួរនេះ ។

ពេលដែល ហ៊ីលីពីន ស៊ុតហ្ស៍ រៀបនឹងឆ្លើយទៅកាន់មេធាវី ខារណាវ៉ាស សាក្សី ប្រាក់ យុត បានជំទាស់ និងបានផ្តល់យោបល់ទាក់ទងទៅនឹងប្រធានបទនោះ ។ ប្រាក់ យុត បាននិយាយថា ក្នុងស្រុកកំពង់សៀម តួនាទីរបស់គាត់គឺដើម្បីអប់រំប្រជាជន តែគាត់មិនដឹងអំពីការសម្លាប់នៅភ្នំប្រុសទេ ហើយគាត់និយាយតែពីតួនាទីរបស់គាត់ប៉ុណ្ណោះ ។

ត្រង់ចំណុចនេះ ចៅក្រមបានពិគ្រោះគ្នាម្តងទៀត បន្តិចក្រោយមក ចៅក្រម និល ណុន បាននិយាយថា ពេលវេលារបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ហើយ ចៅក្រមបានផ្តល់តួនាទីនេះទៅក្រុមការពារក្តីរបស់ នួន ជា ដើម្បីសួរសំណួរទៅកាន់ ប្រាក់ យុត ។

## ក្រុមការពារក្តី នួន ជា លើកឡើងអំពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល

មេធាវី ម៉ៃឃើល ផេស្តមែន របស់ នួន ជា ចាប់ផ្តើមសួរសំណួរដោយសួរអំពីតួនាទីរបស់គាត់មួយទៀតដែលទទួលបន្ទុកខាង"កិច្ចការនារី" ។ ប្រាក់ យុត បានទទួលស្គាល់ថា គាត់ធ្លាប់កាន់

តំណែងនេះ ។ មេធាវី ផេស្តមែន បានសួរទៅសាក្សីថាតើមានដែលជួបជាមួយកម្មាភិបាលតំបន់ផ្សេង ទៀតនៅក្នុងភូមិភាគដែលទទួលបន្ទុកខាងកិច្ចការនារីដែរឬទេ? ប្រាក់ យុត បានបញ្ជាក់ថា មានកិច្ចប្រជុំមួយក្នុងតំបន់៣៥ តែអ្នកដែលមកពីតំបន់ផ្សេងមិនចូលក្នុងក្នុងកិច្ចប្រជុំនេះទេ ។

ក្រោយមក មេធាវីបានសួរទៅអ្នកដែលសាក្សីធ្លាប់ធ្វើការជាមួយ នៅក្នុងភូមិភាគរបស់គាត់ ។ ប្រាក់ យុត បានបញ្ជាក់ថា មនុស្សម្នាក់បានស្លាប់បាត់ទៅហើយ ។ នៅពេលដែលមេធាវីសួរថាតើ តើនរណាដែលនៅរស់ ប្រាក់ យុត បានឆ្លើយដោយកែសម្តីវិញថា កម្មាភិបាលទាំងអស់បានស្លាប់អស់ហើយ ហើយបើទោះជាអ្នកនោះនៅរស់ ក៏គាត់មិនមានទំនាក់ទំនងជាមួយដែរក្រោយពីរបបខ្មែរក្រហមនោះ ។

ក្រោយមក មេធាវីបានសួរត្រលប់ទៅកាន់ប្រធានបទនៃកិច្ចជាមួយអ្នកតំណាងដែលជាស្ត្រី ហើយមេធាវីបានសួរទៅសាក្សីថាមានដែលបានជួបជាមួយ អ៊ឹម ចែម ដែលទទួលបន្ទុកខាងកិច្ចការនារីក្នុងតំបន់១៣ដែរឬទេ? ប្រាក់ យុត បានបញ្ជាក់ថា គាត់បានចូលរួមកិច្ចប្រជុំកិច្ចការនារីម្តង ហើយកាលនោះ អ៊ឹម ចែម ប្រហែលជាចូលរួមដែរ ។ ក្រោយមក មេធាវី ផេស្តមែន បានសួរអំពីការសម្ភាសរវាងសាក្សីនិងអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ មេធាវីបានសួរទៅ ប្រាក់ យុត អំពីអ្វីដែលគាត់និយាយទៅកាន់អ្នកស៊ើបអង្កេតនោះថា តាអាន គឺជាសមាជិកតំបន់៣៥ ។ ប្រាក់ យុត បានឆ្លើយថា គណៈតំបន់មានគ្នារហូតដល់ប្រាំបួននាក់ ហើយគាត់មិនចាំច្បាស់ទេថា តាអាន គឺជាសមាជិកមួយដែរឬក៏អត់នោះ ។

មេធាវី ផ្តេសមែន បានសួរបន្តទៀតថា ហេតុអ្វីបានជាសាក្សីមិនចង់និយាយឈ្មោះ តាអាន នៅពេលដែលនិយាយពីគណៈតំបន់៣៥ពេលដែលកំពុងផ្តល់សក្ខីកម្ម ។ ប្រាក់ យុត មិនដឹងចម្លើយច្បាស់ទេ ហើយហាក់បីដូចជាស្ទាក់ស្ទើរមិនចង់ឆ្លើយដែរ ។ ក្រោយមក មេធាវី ផេស្តមែន សួរទៅសាក្សីអំពីតួនាទីរបស់ តាអាន ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក្រោយពីសាក្សីនិងគាត់បានធ្វើការជាមួយគ្នាជាគណៈតំបន់៣៥ ។ ប្រាក់ យុត បានឆ្លើយថា គាត់មិនច្បាស់ទេថា តាអាន នៅរស់ឬអត់នោះ ។ មេធាវី ផេស្តមែន បានសួរទៅថាហេតុអ្វីបានជាមិនដឹងខណៈពេលដែល តាអាន រស់នៅ តែប្រមាណជា៣០គីឡូម៉ែត្រពីខ្លួនឯងប៉ុណ្ណោះនោះ ។ ប្រាក់ យុត បានឆ្លើយថា គាត់មិនដែលបានទំនាក់ទំនងជាមួយ តាអាន ទេហើយក៏មិនដឹងថាគាត់នៅរស់ទីណាដែរនៅពេលនេះ ។

មេធាវីបានសួរបន្តទៀតថាតើ ប្រាក់ យុត ខ្លាចផ្តល់សក្ខីកម្មទាក់ទងនឹង តាអាន ដែរឬទេ? ប្រាក់ យុត បានឆ្លើយថា គាត់“មិនខ្លាចនឹងនិយាយអំពី តាអាន ទេ” ហើយគាត់និង តាអាន បាន

បែកគ្នាក្រោយពីពេលដែល “យួន” ឈ្លានពានចូលមក តាំងពីពេលនោះមក គាត់មិនដែលមានទំនាក់ទំនងអ្វីសោះ ។

ក្រោយមក មេធាវីបានសួរទៅ ប្រាក់ យុត ថា “តើមានដែលឮពីករណី០០៤នៅតុលាការនេះដែរឬទេ”? សំណួរនេះត្រូវបានជំទាស់ដោយអង្គជំនុំជម្រះភ្លាម ហើយចៅក្រម និល ណុន បានបញ្ជាក់ថា សំណួរនេះមិនពាក់ព័ន្ធទៅនឹងដំណាក់ដំបូងនៃករណី០០២ទេ ។ ទោះបីជាដូច្នេះក៏ដោយ ក៏មេធាវី ផេស្តមែន នៅតែបន្តសួរទៅសាក្សីទៀតថា “យ៉ាងម៉េចដែរបើសិនជាខ្ញុំជម្រាបថា តាអាន ហើយនិង អ៊ឹម ចែម គឺជាជនសង្ស័យក្នុងករណី០០៤នោះ?” សំណួរនេះត្រូវបានបង្អាក់ដោយអង្គជំនុំជម្រះទៀត ហើយចៅក្រម និល ណុន បានរំឭកទៅមេធាវី ផេស្តមែន ថា គាត់ត្រូវតែសួរឲ្យឋិតក្នុងវង្វង់ប្រធានបទ ហើយមេធាវីគួរតែ“ដឹងច្បាស់”ពីបញ្ហានេះ ។ មេធាវី ផេស្តមែន បានធ្វើការពន្យល់ថា គាត់កំពុងតែសួរដេញសាក្សីដោយមិនមែនដើម្បីរកហេតុការណ៍ពិតណាមួយទេ ហើយមេធាវីបានបញ្ជាក់ថា“ខ្ញុំនៅទីនេះ គឺដើម្បីនិយាយពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងករណី០០២” ។ ចៅក្រម ខាត់ព្រាយតិ៍ បានជំទាស់ហើយហាក់បីដូចជាធុញទ្រាន់ទៅនឹងភាពមានះរបស់មេធាវី ផេស្តមែន ហើយចៅក្រមបានរំឭកទៅមេធាវីថា តួនាទីរបស់គាត់គឺដើម្បី“តំណាងឲ្យកូនក្តីរបស់ខ្លួននៅក្នុងសវនាការនេះ” ។ ក្រោយមក មេធាវី ផេស្តមែន បានសួរទៅសាក្សី ប្រាក់ យុត បន្តទៀតថា មាននរណាទៅជួបគាត់ដែរឬទេ មុននឹងមកធ្វើសក្ខីកម្មនេះ? តើមានដឹងទេថា រដ្ឋាភិបាលបានប្រឆាំងនឹងការកាត់ទោសករណី០០៤បន្ថែមទៀតនោះ ។ សំនួរនេះធ្វើឲ្យព្រះរាជអាជ្ញាជំទាស់ដោយអះអាងថា “មានមនុស្សមួយចំនួនតូចប៉ុណ្ណោះ”នៅក្នុងតុលាការនេះ ដែលដឹងពិតប្រាកដទាក់ទងទៅនឹងករណី០០៤ ។ មេធាវី ផេស្តមែន បានឆ្លើយតបទៅនឹងការជំទាស់នេះ ដោយអះអាងបញ្ជាក់ថា “នរណា”ក៏ដឹងច្បាស់ដែរពីករណី០០៤ ដែលអាចរកបានតាមប្រព័ន្ធអ៊ិនធើណែត ។

មេធាវីបានបញ្ជាក់ថា “ខ្ញុំមានជំនឿថា សាក្សីរូបនេះមិនបានធ្វើសក្ខីកម្មដោយពេញលេញទេ” ព្រោះតែការជំទាស់របស់រដ្ឋាភិបាលក្នុងករណី០០៤ ។

ចៅក្រម និល ណុន មិនបានរីករាយនឹងការអះអាងរបស់មេធាវីនេះទេ ហើយបានណែនាំទៅគាត់ថា ឲ្យកំណត់សំណួររបស់ខ្លួនឲ្យច្បាស់ទាក់ទងទៅនឹងដំណាក់កាលដំបូងនៃករណី០០២ ។ ក្រោយមក ចៅក្រម និល ណុន បានប្រគល់តួនាទីនេះទៅចៅក្រម ខាត់ព្រាយតិ៍ ដើម្បីសួរសំណួរខ្លះទៅកាន់សាក្សី ប្រាក់ យុត មុននិងមេធាវីរបស់ នួន ជា សួរបន្ត ។

ចៅក្រម ខាត់ព្រាយតិ៍ បានសួរទៅ ប្រាក់ យុត ដោយត្រង់ៗថា “តើមាននរណាគំរាមអំពីការផ្តល់សក្ខីកម្មនេះទេនៅថ្ងៃនេះ”? ប្រាក់ យុត បានឆ្លើយថា “ខ្ញុំមកទីនោះ គ្មាននរណាគំរាមខ្ញុំ

ទេ» ។ ចៅក្រម ខាត់ព្រាយតី បានសួរទៅសាក្សីថា តើមាននរណាម្នាក់និយាយ«ត្រូវប្រយ័ត្នខ្លួន» មុនពេលមកធ្វើសក្ខីកម្មដែរឬទេ។ សាក្សី ប្រាក់ យុត បានបដិសេធថាមិនមាននរណានិយាយអ្វីមកកាន់គាត់ទេ «គ្មានបង្គាត់គាត់ប្រាប់គាត់ឲ្យនិយាយទេ» ។

ចៅក្រម និល ណុន បានប្រកាសសម្រាកនៅពេលរសៀល ។

ក្រោយពីសម្រាករួច ចៅក្រម និល ណុន បានបញ្ជាក់ថា ប្រសិនបើមេធាវីរបស់ នួន ជា មានសំណួរចង់សួរទៅសាក្សីគឺអាចសួរបានទៅពេលនេះ ។ មេធាវី ដេស្តមែន បានបញ្ជាក់ថា ខ្លួនមិនមានសំណួរអ្វីទៀតទេ តែគាត់ចង់និយាយខ្លះអំពីការសួរសំណួរទៅកាន់សាក្សី ប្រាក់ យុត អំពីការដឹងឮរបស់គាត់ទាក់ទងទៅនឹងករណី០ ០ ៤ ។

មេធាវី ដេស្តមែន បានបញ្ជាក់ថា មេធាវីការពារក្តីមានតួនាទីនិងសួរសាក្សី ចៅក្រម មិនមានកិច្ចការអ្វីនឹង«មកជួយ» ពេលដែលសាក្សីកំពុងតែត្រូវបានសួរទេ ។ ល្អិតណាសំណួរនោះឋិតនៅក្នុងវង្វង់ច្បាប់ក្រុមរបស់ នួន ជា អាចសួរបានដោយសេរី ។ ក្រោយមក មេធាវី ដេស្តមែន បាន«ព្រមាន» ទៅអង្គជំនុំជម្រះថា ក្រុមការពារក្តី នឹងបន្តសួរសំណួរទាក់ទងនឹងបញ្ហានេះទៀតចំពោះការជ្រៀតជ្រែកផ្នែកនយោបាយ ហើយនេះ គឺជាទិដ្ឋភាពសំខាន់នៃយុទ្ធសាស្ត្រនេះ ។

ដា លីសាក់ បានបញ្ជាក់សារឡើងវិញអំពីគោលជំហររបស់ព្រះរាជអាជ្ញា ដោយអះអាងថា មេធាវី ដេស្តមែន បានជ្រៀតជ្រែកសាក្សីដោយស្នើថា ប្រាក់ យុត អាចទទួលឥទ្ធិពលមិនត្រឹមត្រូវបើសិនជាសួរមិនត្រូវចំណុច ។ ជំហររបស់ព្រះរាជអាជ្ញាចង់បញ្ជាក់ថា ចៅក្រម ខាត់ព្រាយតី បានធ្វើត្រូវហើយដែលសួរទៅសាក្សីដើម្បីទទួលព័ត៌មានបន្ថែមនោះ ។

ត្រង់ចំណុចនេះ ចៅក្រម ហ្សង់ម៉ាក្ស ឡាវ៉ែញ បានសួរទៅភាគីដើមបណ្តឹងរដ្ឋប្បវេណីថា តើឯកសារដែលបានលើកឡើងកាលពីលើកមុនមានបានបកប្រែទៅជាបីភាសាហើយឬនៅ ហើយហេតុអ្វីបានជាចង់ប្រើប្រាស់ឯកសារនេះ ។ ហ៊ីលីពីន ស៊ុតហ្ស៍ បានឆ្លើយតបថា ឯកសារខ្លះត្រូវបានបកប្រែរួចហើយ តែមិនមែនឯកសារទាំងអស់ត្រូវបានបញ្ជូនដោយដើមបណ្តឹងរដ្ឋប្បវេណីទេ ដូច្នេះឯកសារខ្លះមិនទាន់មានការបកប្រែនៅឡើយទេ ។ ហ៊ីលីពីន ស៊ុតហ្ស៍ បានបន្ថែមទៀតថា គោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្រើប្រាស់ឯកសារនេះ គឺដើម្បីជួយពិនិត្យរកមើលអំពីសង្វាក់នៃការបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងរចនាសម្ព័ន្ធទំនាក់ទំនងទាក់ទងទៅនឹងការសម្លាប់ ។

ក្រោយពីបញ្ជាក់ឲ្យច្បាស់រួចមក ចៅក្រម ខាត់ព្រាយតី បានសួរសំណួរបន្ថែមទៀតទៅកាន់សាក្សី ប្រាក់ យុត ។ ដំបូង ចៅក្រមបានសួរថាតើគោលវាសនារបស់សាក្សីយ៉ាងម៉េចដែរ ក្រោយពីប្តីរបស់គាត់ត្រូវបានចាប់ខ្លួននោះ ។ ប្រាក់ យុត បានឆ្លើយថា «បើសិនជាគាត់គវ៉ានោះ ជីវិតគាត់និង

មានបញ្ហាមិនខាន» ហើយថា ទោះបីជាការចាប់ខ្លួននោះធ្វើឲ្យគាត់រងទុក្ខសង្វេគក៏ដោយ ក៏គាត់«ត្រូវតែលះបង់» និង«មិនយំទេ នៅពេលដែលប្ដីរបស់គាត់ត្រូវបានចាប់ខ្លួន» ។

## ចៅក្រម ខាត់ព្រាយត៍ សួរទៅសាក្សី

ក្រោយពីចៅក្រម ខាត់ព្រាយត៍ សួរសំណួរ ប្រាក់ យុត បានបញ្ជាក់ថា តាមគំនិតរបស់គាត់ វាជារឿង«ខុស»ក្នុងការបង្ខំប្រជាជនឲ្យធ្វើការច្រើន តែពេលបដិវត្តន៍ គាត់ជឿថា «យើងត្រូវតែធ្វើតាមផែនការរបស់ថ្នាក់លើ» ។ ទោះបីជាមានរឿងអ្វីកើតឡើងចំពោះអ្នកដែលមិនទទួលបានការ«អប់រំ»ដោយជោគជ័យក៏ដោយ តែគាត់បានបញ្ជាក់ថា «មិនមានការសម្លាប់មនុស្សទេ ព្រោះអ្នកទាំងនោះគ្រាន់តែសាងកំហុសតិចតួចប៉ុណ្ណោះ» ។

ទាក់ទងទៅនឹងការចាប់ខ្លួននៅថ្នាក់លើ ប្រាក់ យុត បានឆ្លើយថា «វាជាការពិត» ដែលអំពើសម្លាប់បានកើតឡើង។ ចៅក្រម ខាត់ព្រាយត៍ បានអាននូវអ្វីដែលសាក្សី ប្រាក់ យុត បានផ្ដល់បទសម្ភាសទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា កម្មាភិបាលតាមមូលដ្ឋាន«រៀបចំបញ្ជី»របស់អ្នកដែលសង្ស័យថាក្បត់ និងអ្នកដែលឈ្លានពានដល់គោលការណ៍បក្សកុម្មុយនីស្តកម្ពុជា ហើយថ្នាក់ក្រោមជាអ្នកបញ្ជូនព័ត៌មាននោះទៅថ្នាក់លើ ។ ប្រាក់ យុត បានទទួលស្គាល់ថា គាត់បាននិយាយបែបនេះមែន ហើយគាត់និយាយអស់ពីចិត្ត ។

## មេធាវីរបស់ អៀង សារី និង ខៀវ សំផន មិនសួរសំណួរទៅកាន់សាក្សី

ចៅក្រម ខាត់ព្រាយត៍ បានបញ្ចប់ការសួរនាំ ហើយបន្ទាប់មក ក្រុមការពារក្ដីរបស់ អៀង សារី និង ខៀវ សំផន ត្រូវបានជូនឱកាសដើម្បីសួរទៅកាន់សាក្សី ។ មេធាវីទាំងពីរបានបដិសេធមិនសួរសំណួរទៅសាក្សី ប្រាក់ យុត ទេ ។ ចំណុចនេះអាចអនុញ្ញាតឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចសួរសំណួរបន្ថែមទៀតដោយសំអាងលើការដាក់ពាក្យសុំរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងអ្វីដែលសាក្សីរូបនេះបាននិយាយ ។

## អង្គជំនុំជម្រះពិចារណា និងជំទាស់ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការប្រើប្រាស់ឯកសារក្នុងការសួរសំណួរ

ក្រោយពីពិគ្រោះគ្នារួចមក ចៅក្រម ឡាវើញ បានត្រលប់មកនិយាយពីភាគីដើមបណ្ដឹងរដ្ឋប្បវេណីថា តើឯកសារដែលចង់យកមកប្រើនោះមានបកប្រែជាភាសារខ្មែរ, បារាំង និងអង់គ្លេសហើយឬនៅ? ត្រង់ចំណុចនេះ មេធាវីរបស់ ខៀវ សំផន សុំមើលឯកសារដើមជាជាងការសង្ខេបរបស់ឯកសារនោះ តែមិនទាន់មាននៅក្នុងប្រព័ន្ធកុំព្យូទ័រនៅឡើយទេ ។

*ហ៊ីលីពីន ស៊ិតហ្វ៍ បានបញ្ជាក់ឲ្យច្បាស់ថា មានតែឯកសារសង្ខេបទេដែលមានជាភាសាបារាំង និងអង់គ្លេស តែមិនទាន់មានជាភាសាខ្មែរទេ ។ គាត់បាននិយាយទៀតថា ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនមិនបានបកប្រែទេ ហើយឯកសារនោះ គឺមានយថាភាព អាចទុកចិត្តបាន និងមានការពាក់ព័ន្ធនឹងសំណុំរឿង ។*

*ចៅក្រម និល ណុន បានជំទាស់ភ្លាមៗដែរដោយបញ្ជាក់ថា ព្រោះឯកសារនោះមិនទាន់មានការបកប្រែជាភាសាផ្សេង តែមិនទាន់មានជាភាសាខ្មែរ ឯកសារនោះមិនអាចយកមកប្រើបានទេ ។ ក្រោយមក ចៅក្រម និល ណុន បានសុំទោសដល់សាក្សី ប្រាក់ យុត បន្ទាប់មកចៅក្រមបានប្រកាសបញ្ចប់នៅពេលនេះ ។ កម្មវិធីនឹងបន្តនៅថ្ងៃស្អែកបន្តទៀតនៅវេលាម៉ោង9:០០ព្រឹក ។*

**-ចប់-**